# ការរួបរួម ?

នៅក្នុង ស្ថានភាពនយោបាយតឹងរ៉ឹងសព្វថ្ងៃ ជនខ្មែរមួយចំនួន ធ្វើការអំពាវនាវឱ្យ ពួកអ្នកកាន់អំណាច និង ពួកអ្នកប្រឆាំង រួបរួមគ្នា ដើម្បីដោះស្រាយបញ្ហានយោបាយ ជាពិសេសបញ្ហាទណ្ឌកម្មអន្តរជាតិ ដែលវា នឹងអាចកើតឡើងបាននៅពេលឆាប់ៗនេះ។ ការអំពាវនាវនេះ វាស្របទៅនឹងការចង់បានរបស់អង្គការសហប្រជាជាតិ និង សហគមអន្តរជាតិ ព្រោះវាជាគោលការណ៍ដាច់ខាត នៃដំណោះស្រាយតាមសន្តិវិធី។ ជាការពិត ការចរចា វាអាចនឹងប្រព្រឹត្តិទៅបាន លុះណាវាមានមូលដ្ឋាន និង គោលដៅវាច្បាស់លាស់គឺ យកច្បាប់ត្រឹមត្រូវ និង សីលធម៌ជាលក្ខខណ្ឌដាច់ខាត។ តែថា នៅក្នុងជម្លោះខ្មែរនិងខ្មែរ វាមាន អ្នកបំពានច្បាប់ និង សីលធម៌ និង អ្នករងគ្រោះ ឬ អ្នកខ្លាំង និង អ្នកខ្សោយ ដែលបង្កើតជាលក្ខខណ្ឌ នៃភាពមិនស្មើគ្នា ដែលនឹងអាចនាំឱ្យការចរចា ប្រព្រឹត្តិទៅលើផ្លូវទំនាល់ ឬ នៅក្នុងស្ថានភាពមាន អ្នកឈ្នះ និង អ្នកចាញ់ ដោយមានការចុះចាញ់ ឬ ចុះចូល ពីសំណាក់អ្នកខ្សោយដូចសព្វដង។ នៅក្នុងស្ថានការណ៍ (scénario) បែបនេះ តើគេអាចទុកជាការរួបរួមគ្នាបានដែរឬទេ ? វាអាចទុកបាន លុះណាតែដំណោះស្រាយនោះ វាស្ថិតនៅក្នុងគោលការណ៍ គោរពច្បាប់ត្រឹមត្រូវ និង សីលធម៌។ ពុំនោះសោធ វាគ្រាន់តែជាការសម្របសម្រួល ដើម្បីគ្រាន់តែចែកប្រយោជន៏គ្នាតែប៉ុណ្ណោះ ដូចធ្លាប់មានរួចមកហើយ ដែលជាស្ថានភាពអាក្រក់បំផុតសំរាប់ប្រជាជាតិ។ ដើម្បីវៀរចាកការណ៍នេះ វាមានតែទុកប្រជាពលរដ្ឋជាអធិបតី ដែលជាលក្ខខណ្ឌតែមួយគត់សំរាប់ការរួបរួម កើតចេញពីការបោះឆ្នោតដោយសេរី និង ដោយយុត្តិធម៌ ព្រោះប្រជាជនខ្មែរនាំគ្នារួបរួមគ្នាទៅបោះឆ្នោត ដើម្បីជ្រើសរើសអ្នកដឹកនាំជាតិ។ ដំណោះស្រាយនេះ វាមានទិដ្ឋភាពសាមញ្ញ តែចំពោះពួកផ្តាច់ការ គេទុកវាជាដំណោះស្រាយ ដែលមិនអាចធ្វើបាន, ហេតុអ្វី ? ហើយត្រូវធ្វើដូចម្តេចវិញ ? និរោធលោក វង្សី ?